World Health Organization
Western Pacific Region

# កម្ពុជា

## របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ លេខ#៨៧

របាយការណ៍គិតត្រឹមថ្ងៃទី ៦ ខែមិថុនា ឆ្នាំ២០២២ ម៉ោង១០:00នាទីព្រឹក

## ស្ថានការណ៍សង្ខេបសំខាន់ៗ (ថ្ងៃទី២ ឧសភា ដល់ថ្ងៃ ៥ មិថុនា ឆ្នាំ២០២២)*

- ករណីវិជ្ជមានវីរុសកូវីដ-១៩ថ្មី បញ្ជាក់ដោយ PCR សរុបចំនួន ៨ ត្រូវបានរាយការណ៍នៅកម្ពុជានៅចន្លោះពេលពីថ្ងៃទី ២ ខែឧសភា ដល់ថ្ងៃទី ៥ខែមិថុនា។ ករណីទាំងអស់នេះ ជាករណីឆ្លងក្នុងសហគមន៍។
- គិតត្រឹមថ្ងៃទី ៥ ខែមិថុនា ឆ្នាំ២០២២ ករណីសរុបទាំងអស់ចំនួន ១៣៦.២៦២  ត្រូវបានបញ្ជាក់ថាជាករណីវិជ្ជមានវីរុសកូវីដ-១៩ និងករណីស្លាប់ចំនួន ៣.០៥៦ ត្រូវបានរាយការណ៍ដោយរាជរដ្ឋាភិបាលកម្ពុជាចាប់តាំងពីថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២០មក។ ក្នុងចំណោមនោះ  ១៣៣.២០៥ករណីបានជាសះស្បើយ។
- គិតត្រឹមថ្ងៃទី ៥ ខែមិថុនា ឆ្នាំ២០២២ តេស្តសរុបចំនួន ២.៦២៣.៨៣៧ត្រូវបានធ្វើដោយប្រើម៉ាស៊ីនតេស្តមន្ទីរពិសោធន៍ (RT-PCR)  នៅកម្ពុជា។ រយៈពេលពីថ្ងៃទី ២ ខែឧសភា ដល់ថ្ងៃទី ៥ខែមិថុនា បានធ្វើតេស្តចំនួន ៧.៥៣៧ រកវីរុសកូវីដ-១៩ ដោយប្រើបច្ចេកវិទ្យាធ្វើតេស្តប្រើម៉ាស៊ីននៅមន្ទីរពិសោធន៍ (Reverse-Transcriptase Polymerase Chain Reaction, RT-PCR) ។
- ក្នុងរយៈពេលរាយការណ៍នេះដែលគិតចាប់ពីថ្ងៃទី ២ ខែឧសភា ឆ្នាំ២០២២មក វ៉ាក់សាំងកូវីដ-១៩ជិត ១,៧សែនដូសត្រូវបានចាក់ជូនដល់ក្រុមកុមារដែលមានសិទ្ធិទទួលបានវ៉ាក់សាំងអាយុចាប់៣ឆ្នាំឡើង។ ៨៩,៦ភាគរយនៃចំនួនប្រជាជនសរុបទទួលបានវ៉ាក់សាំង២ដូស ហើយចំនួន ៥៨ភាគរយទទួលបានវ៉ាក់សាំងដូសជម្រុញយ៉ាងហោចណាស់មួយដូស។
- ការអង្កេតតាមដានជំងឺដោយប្រើព័ត៌មានពហុប្រភព បង្ហាញថាស្ថានភាពពីដេមីសាស្ត្រនៅកម្ពុជាមានស្ថេរភាព។ មិនមានករណីឆ្លងជាចង្កោមត្រូវបានរកឃើញទេ មានការធ្លាក់ចុះនូវចំនួននៃការហៅចូលលេខទូរស័ព្ទទាន់ហេតុការណ៍ ១១៥ អំពីកូវីដ-១៩ មានការធ្លាក់ចុះនូវចំនួនតេស្តវិជ្ជមានរួមទាំងប្រព័ន្ធអង្កេតតាមដានជំងឺសង់ទីណែល និងមិនមានការកើនឡើងនូវករណីព្យាបាលនៅមន្ទីរពេទ្យ។ មិនមានករណីស្លាប់ដោយជំងឺកូវីដ-១៩ត្រូវបានរាយការណ៍ចាប់តាំងពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២មក។
- បើទោះបីជាស្ថានភាពនៃការឆ្លង កំពុងតែមានស្ថេរភាពក៏ដោយ ក៏ការគ្រប់គ្រងបញ្ហាកូវីដ-១៩ប្រកបដោយនិរន្តរភាពមានសារៈសំខាន់ រួមទាំងវិធានការដើម្បីធានាឱ្យមានប្រព័ន្ធតាមដានករណីឆ្លងកូវីដ-១៩ត្រូវដំណើរការដើម្បីតាមដានកម្រិតចម្លង និងធានាថាមានយុទ្ធសាស្ត្រសម្រាប់វិធានការសុខាភិបាល និងសង្គមមានរួចរាល់ ប្រសិនបើស្ថានការណ៍ប្រែប្រួល និងធានាឱ្យមានកិច្ចខិតខំប្រឹងប្រែងដើម្បីកសាងសមត្ថភាពថ្នាក់មូលដ្ឋានសម្រាប់ការឆ្លើយតបនៅថ្នាក់មូលដ្ឋាន។

## ការរកឃើញបានឆាប់ និងឆ្លើយតបចំគោលដៅ

- និយមន័យករណីជំងឺកូវីដ-១៩ កំពុងត្រូវបានធ្វើបច្ចុប្បន្នភាពដើម្បីដាក់បញ្ចូលរោគសញ្ញា និងលក្ខខណ្ឌអេពីដេមីសាស្ត្រទូលំទូលាយជាងមុនបន្ថែមទៀត។
- ដើម្បីគាំទ្រការអង្កេតតាមដានជំងឺ (រួមទាំងការអង្កេតតាមដានហ្សេណូម) បណ្តាខេត្តត្រូវបានលើកទឹកចិត្តឱ្យប្រមូលសំណាករហូតដល់១៥ក្នុងមួយសប្តាហ៍សម្រាប់តេស្តរកមេរោគកូវីដ-១៩ដោយមានការគាំទ្រផ្នែកយុទ្ធសាស្ត្រអំពីការធ្វើតេស្តពីអង្គការសុខភាពពិភពលោក និងមជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺរបស់សហរដ្ឋអាមេរិក។

## វិធានការសុខាភិបាល និងសង្គម

- ការពាក់ម៉ាស នៅតែជាកាតព្វកិច្ចសម្រាប់ទីកន្លែងខាងក្នុង និងទីកន្លែងបិទជិត ដូចជាបន្ទប់ប្រជុំ និងរោងកុន។
- យុទ្ធសាស្ត្រសម្រាប់វិធានការសុខាភិបាល និងសង្គម កំពុងតែត្រូវបានអភិវឌ្ឍដើម្បីគាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្តរួមទាំងវិធានការដែលត្រូវដាក់ចេញ និងលក្ខខណ្ឌ។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩  ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

## ការប្រាស្រ័យទាក់ទងអំពីហានិភ័យ និងការចូលរួមរបស់សហគមន៍

- មជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព នឹងផ្តួចផ្តើមផែនការអនុវត្តការកសាងសមត្ថភាព "សម្រាប់ជម្រុញការចូលរួមរបស់សហគមន៍នៅក្នុងការពង្រឹងការអង្កេតតាមដានករណីឆ្លងកូវីដ-១៩ ផ្តាសសាយធំ និងភ្នាក់ងារបង្ករោគផ្លូវដង្ហើមផ្សេងទៀត"ចាប់ពីថ្ងៃទី ១៥ ខែមិថុនាតទៅ។ សិក្ខាសាលាតម្រង់ទិញ នឹងត្រូវរៀបចំឡើងសម្រាប់ខេត្តអាទិភាពជាពីរក្រុមនៅខេត្តកំពង់ធំ និងខេត្តកំពង់ចាមនៅថ្ងៃទី ១៥ និង ១៦ កក្កដា។
- អង្គការសុខភាពពិភពលោក កំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងដៃគូសុខាភិបាល និងភ្នាក់ងារអង្គការសហប្រជាជាតិដើម្បីបន្តចែកចាយសារផ្អែកលើហានិភ័យអំពីវិធានការសុខាភិបាល និងសង្គម និងជម្រុញការចាក់វ៉ាក់សាំងដូសជម្រុញ ជាពិសេសផ្តោតលើទីតាំងមានហានិភ័យ និងក្រុមប្រជាជនងាយរងគ្រោះ។ អង្គការសុខភាពពិភពលោក កំពុងគាំទ្រក្រសួងសុខាភិបាលក្នុងការអភិវឌ្ឍផែនការកសាងសមត្ថភាពក្នុងការប្រាស្រ័យទាក់ទងអំពីហានិភ័យដល់រាជធានី-ខេត្តទាំង២៥ ដើម្បីបន្តឆ្លើយតបចំពោះកូវីដ-១៩ និងសម្រាប់ការត្រៀមលក្ខណៈនាពេលអនាគត។

## ការចាក់វ៉ាក់សាំង

- យុទ្ធនាការជម្រុញការវ៉ាក់សាំងកូវីដ-១៩ បានបន្តតាមរយៈសកម្មភាពចុះផ្តល់ថ្នាំបង្ការដោយមានការគាំទ្រពហុវិស័យរួមទាំងការចាក់វ៉ាក់សាំងតាមផ្ទះ និងក្រៅម៉ោងធ្វើការ ដើម្បីចាក់ជូនដល់ប្រជាជនងាយរងគ្រោះដូចជាអ្នកដែលមានពិការភាព មនុស្សចាស់ និងពលករ។
- សម្តេចនាយករដ្ឋមន្ត្រី បានបញ្ជាក់ ហើយគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងទូទាំងប្រទេសបានប្រកាសអំពីយុទ្ធនាការចាក់វ៉ាក់សាំងដូសទី៥ចាប់ផ្តើមពីថ្ងៃទី ៩ខែមិថុនា ឆ្នាំ២០២២ ដល់បុគ្គលិកសុខាភិបាល និងមន្ត្រីរដ្ឋាភិបាលជួរមុខ មនុស្សចាស់ដែលមានអាយុចាប់ពី ៦០ឡើង អ្នកដែលមានជំងឺប្រចាំកាយ កងកម្លាំងប្រដាប់អាវុធ មន្ត្រីការទូត មន្ត្រីអង្គការសហប្រជាជាតិជាដើមដែលបានចាក់វ៉ាក់សាំងដូសទី៤រួចហើយចន្លោះពី៣ទៅ៤ខែ។
- ការគាំទ្ររបស់អង្គការសុខភាពពិភពលោកទៅកម្មវិធីជាតិផ្តល់ថ្នាំបង្ការៈ
    - ការគាំទ្រផ្នែកបច្ចេកទេសនៅក្នុងការធ្វើផែនការលទ្ធកម្ម ពិធីសារ/គោលការណ៍ណែនាំបច្ចេកទេសគោលនយោបាយ ការបណ្តុះបណ្តាល ការត្រួតពិនិត្យ និងអភិបាលកិច្ច និងការបង្ហាត់បង្ហាញដោយផ្ទាល់នៅនឹងកន្លែងសម្រាប់ការផ្តល់វ៉ាក់សាំងកូវីដ-១៩ ប្រកបដោយប្រសិទ្ធភាព (ខេត្តចំនួន៥ត្រូវបានត្រួតពិនិត្យនៅក្នុងរយៈពេលរាយការណ៍)
    - ការគាំទ្រផ្នែកថវិកាដល់ខេត្តចំនួន៧ដែលមានភូមិ/ឃុំដែលពិបាកចុះទៅដល់ដើម្បីចុះធ្វើសកម្មភាពផ្តល់ថ្នាំបង្ការ។

## ការផ្តល់ និងមាតាំថែទាំសុខភាព

- ក្រោយពេលដាក់ចេញគោលការណ៍ណែនាំអំពីការបញ្ចូលសេវាចាក់វ៉ាក់សាំងកូវីដ-១៩ទៅក្នុងប្រព័ន្ធថែទាំសុខភាពដែលមានស្រាប់ នាយកដ្ឋានមន្ទីរពេទ្យ បានចាប់ផ្តើមសកម្មភាពបង្ហាត់បង្ហាញទៅដល់មន្ទីរពេទ្យថ្នាក់ក្រោមជាតិដើម្បីគាំទ្រការធ្វើសមាហរណកម្មនេះ។ ចាប់ពីខែឧសភា ឆ្នាំ២០២២មក សកម្មភាពទាំងនោះបានចាប់ផ្តើមនៅក្នុងខេត្តចំនួន៥ដូចជាខេត្តកោះកុង ខេត្តតាកែវ ខេត្តស្វាយរៀង ខេត្តកំពង់ធំ និងខេត្តព្រៃវែង។
- ការកសាងសមត្ថភាពដោយបង្ហាត់បង្ហាញនៅនឹងកន្លែងអំពីការព្យាបាលដោយប្រើអុកស៊ីសែន និងការប្រើប្រាស់ឧបករណ៍ជំនួយអុកស៊ីសែន កំពុងតែបន្តនៅក្នុងខេត្តព្រៃវែង និងខេត្តស្វាយរៀង។

## វិធានការព្រំដែនអន្តរជាតិ

- នៅថ្ងៃទី ១២ ខែឧសភា រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសថាកម្ពុជា និងវៀតណាម នឹងបើកព្រំដែនឡើងវិញ។



**បដិសេធការទទួលខុសត្រូវៈ** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

## អេពីដេមីសាស្ត្រ

### ក្រាហ្វិកទី១. ខ្សែកោងអេពីដេមិកនៃករណីជំងឺកូវីដ-១៩ បញ្ជាក់ដោយមន្ទីរពិសោធន៍ បែងចែកតាមកាលបរិច្ឆេទនៃរបាយការណ៍ឆ្នាំ ២០២១-២០២២ *




*ចាប់ពីថ្ងៃ ៣០ ខែកញ្ញាឆ្នាំ២០២១មក មានតែលទ្ធផលតេស្តវីរុសកូវីដ-១៩ បញ្ជាក់ដោយ PCR ប៉ុណ្ណោះដែលត្រូវបានរាយការណ៍ជាចំនួនករណីឆ្លងផ្លូវការ។ ការតម្រូវធ្វើតេស្តសម្រាប់អ្នកដំណើរដែលចូលមកកម្ពុជាត្រូវបានលុបចោលចាប់តាំងពីថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០២២។

### តារាងទី១. តារាងសង្ខេបអំពីសូចនាករកូវីដ-១៩

| | | | | |
|---|---|---|---|---|
| **បច្ចុប្បន្នភាពអេពីដេមីសាស្ត្រ អំពីកូវីដ-១៩** | ចំនួនតេស្ត | ករណីឈឺ | ករណីស្លាប់ | |
| | 7,537<br>ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចក្នុងពេល 35 ថ្ងៃចុងក្រោយ | 0<br>ករណីវិជ្ជមានថ្មីក្នុងពេល14 ថ្ងៃចុងក្រោយ | 0<br>ករណីស្លាប់ក្នុងពេល 14ថ្ងៃចុងក្រោយ | 0<br>ករណីនាំចូលក្នុងពេល14 ថ្ងៃចុងក្រោយ |
| | 2,623,837<br>ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចសរុប | 136,262<br>ករណីសរុប | 3,056<br>ករណីស្លាប់សរុប | |

| | | | |
|---|---|---|---|
| **ការផ្តល់សេវាសុខភាព អំពីកូវីដ-១៩** | 79<br>ចំនួនមន្ទីរពេទ្យដែលទទួលព្យាបាលអ្នកជំងឺកូវីដ-១៩ | 145<br>ចំនួនមណ្ឌលព្យាបាលអ្នកជំងឺកូវីដ-១៩ | 1,626<br>ចំនួនគ្រែអ្នកជំងឺធ្ងន់ដែលមាននៅមន្ទីរពេទ្យ និង មណ្ឌលព្យាបាល |



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

**តារាងទី២. យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩តាមក្រុមគោលដៅ (បុគ្គលិកសុខាភិបាល មនុស្សចាស់ មនុស្សពេញ វ័យ និងកុមារ) *ទិន្នន័យគិតត្រឹមថ្ងៃទី ៣ ខែមិថុនា ឆ្នាំ២០២២**

| | បុគ្គលិកសុខាភិបាល | មនុស្សពេញវ័យ | | | យុវវ័យ និងកុមារ | | |
|---|---|---|---|---|---|---|---|
| | | អាយុចាប់ពី ៦០ឆ្នាំ | អាយុចាប់ពី ១៨ឆ្នាំ | អាយុ៣-៥ឆ្នាំ | អាយុ៥ឆ្នាំ | អាយុពី៦ឆ្នាំ ដល់ ១១ឆ្នាំ | អាយុចាប់១២ ឆ្នាំដល់ ១៧ឆ្នាំ |
| | (N=43,646) | (N=1,378,688) | (N=10,000,000) | (N=610,730) | (N=304,317) | (N=1,897,382) | (N=1,827,348) |
| ចាប់ផ្តើម | 10 កុម្ភៈ 2021 | 10 កុម្ភៈ 2021 | 10 កុម្ភៈ:2021 | 22 កុម្ភៈ 2022 | 1 វិច្ឆិកា 2021 | 17 កញ្ញា 2021 | 1 សីហា 2021 |
| ដូសទី១ | 43,646 (100%) | 1,411,594 (102.4%) | 10,320,616 (103.2%) | 409,928 (67.1%) | 405,361 (133.2%) | 2,071,263 (109.2%) | 1,838,827 (100.6%) |
| ដូសទី២ | 43,646 (100%) | 1,395,650 (101.2%) | 9,972,056 (99.7%) | 223,224 (36.6%) | 334,618 (110.0%) | 2,019,965 (106.5%) | 1,778,405 (97.3%) |
| ដូសទី៣ | 43,646 (100%) | 959,794 (69.6%) | 6,512,762 (65.1%) | N/A | 43,247 (14.2%) | 1,257,797 (66.3%) | 1,445,855 (79.1%) |
| ដូសទី៤ | 43,646 (100%) | 192,813 (14.0%) | 2,302,051 (23.0%) | N/A | N/A | N/A | 277,227 (15.2%) |

**N/A: មិនអាចអនុវត្តបាន**

**តារាងទី៣. អត្រានៃហេតុការណ៍កើតមានក្រោយពេលចាក់វ៉ាក់សាំង (AEFI) ក្នុងចំណោម ១០០.០០០ដូស តាមប្រភេទវ៉ាក់សាំង កូវីដ-១៩។ *ទិន្នន័យគិតត្រឹមថ្ងៃទី ៣ ខែមិថុនា ឆ្នាំ២០២២**

| ប្រភេទវ៉ាក់សាំង កូវីដ-១៩ | Sinovac | Sinopharm | AstraZeneca (Covishield) | Janssen (Ad26.COV2-S) | AstraZeneca (Vaxzevria) | Moderna (Spikevax) | Pfizer BioNTech (Comirnary) | សរុប |
|---|---|---|---|---|---|---|---|---|
| ចំនួនករណី | 101 | 79 | 29 | 4 | 1 | 3 | 0 | **217** |
| ចំនួនដូសសរុបបានចាក់ | 25,122,135 | 7,500,126 | 323,344 | 1,053,151 | 3,992,725 | 352,638 | 1,815,932 | **40,160,051** |
| អត្រានៃហេតុការណ៍ក្នុងចំណោម ១០០.០០០ដូស | 0.40 | 1.05 | 8.97 | 0.38 | 0.03 | 0.85 | 0.00 | **0.54** |

## ឯកសារយោង និងតំណរភ្ជាប់ដែលពាក់ព័ន្ធ

- គេហទំព័រក្រសួងសុខាភិបាល: គេហទំព័រផ្លូវការរបស់ក្រសួងសុខាភិបាល
- របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ដោយក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក: របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ចុងក្រោយបំផុតសម្រាប់ប្រទេសកម្ពុជា។
- របាយការណ៍ស្តីពីស្ថានភាពថ្នាក់តំបន់:របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ចុងក្រោយបំផុតសម្រាប់អង្គការសុខភាពពិភពលោក តំបន់ប៉ាស៊ីហ្វិកខាងលិច។
- របាយការណ៍ស្តីពីស្ថានភាពថ្នាក់សាកល: របាយការណ៍បច្ចុប្បន្នភាពស្តីពីកូវីដ-១៩ផ្នែកប្រតិបត្តិការ និងអេពីដេមីសាស្ត្ររបស់អង្គការសុខភាពពិភពលោកថ្នាក់សាកល។
- គោលការណែនាំរបស់អង្គការសុខភាពពិភពលោក: គោលការណែនាំសម្រាប់ប្រទេស និងបច្ចេកទេសអំពីកូវីដ-១៩ចុងក្រោយបំផុតរបស់អង្គការសុខភាពពិភពលោក។
- ក្តារព័ត៌មានឌីជីថលស្តីពីកូវីដ-១៩របស់អង្គការសុខភាពពិភពលោក: ទិន្នន័យកូវីដ-១៩កម្រិតតំបន់ និងពិភពលោកចុងក្រោយបំផុត។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។